STREAM ឆ្នាំទី២ លេខ១ ខែ មករា-មិនា ២០០៣

**Support to Regional Aquatic Resources Management**
**គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់**

# ទស្សនាវដ្ដី *STREAM*

## ការទំនាក់ទំនង និង ការរៀនសូត្រពីជីវភាពរស់នៅរបស់អ្នកនេសាទ និង កសិករ

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

# មាតិកា


**អត្ថបទ** **ទំព័រ**

រៀនឱ្យកាន់តែស៊ីជំរៅពីគំរោងគ្រប់គ្រងធនធានជលផល ១
*Tee-Jay A san Diego*

ការណែនាំឱ្យដឹងពីយុទ្ធវិធី *SIAD* និង ការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋានដោយមានការចូលរួម ៤
*Elizabeth M Gonzales*

ការកសាងក្រុម ជោគជ័យនៃផលិតកម្ម និង ការព្យាយាមដើម្បីការពារនូវការចាប់យកធនធាន ៧
*B K Sahay, K P Singh និង S N Pandeya*

កសិកម្មនៅទីក្រុង ការប្រើប្រាស់ទឹកម្តងទៀត និង សេដ្ឋកិច្ចមូលដ្ឋានៈ ករណីសិក្សា ការតាំងទីលំនៅនៅតំបន់ដែសមុទ្រនៃរដ្ឋ Ondo ប្រទេសនីហ្សេរីយ៉ា ១០
*Yemi Akegbejo-Samsons*

ការវិភាគការចិញ្ចឹមជីវិតៈ បទពិសោធន៍ជាក់ស្តែងពីការប្រើប្រាស់ PRA ១៣
*Pham Minh Tam និង Trinh Quang Tu*

យុទ្ធសាស្ត្រចិញ្ចឹមជីវិតដោយនិរន្តរភាពក្នុងការអភិវឌ្ឍន៍វិស័យជលផលដើម្បីកាត់បន្ថយភាពក្រីក្រនៅភាគអគ្នេយ៍នៃប្រទេសវៀតណាម ១៦
*Nguyen Van Tu និង Nguyen Minh Duc*

ពត៌មានពីទស្សនាវដ្តីរបស់ **STREAM** ១៩

ពត៌មានពី **STREAM** ២១

## **កំណត់ចំណាំៈ**

ទស្សនាវដ្ដី STREAM បានចុះផ្សាយនៅលេខនេះមានអត្ថបទមកពីប្រទេស ហ្វីលីពីន ឥណ្ឌា នីហ្សេរីយ៉ា និង វៀតណាម ដែលផ្ដោតលើជុំវិញបញ្ហាដែល STREAM កំពុងលើកកំពស់ការរៀនសូត្រ និង ទំនាក់ទំនងពីការចិញ្ចឹមជីវិតរបស់កសិករ និង អ្នកនេសាទ។

អត្ថបទទី១ សរសេរដោយលោក Tee-Jay A San Diego នៃប្រទេសហ្វីលីពីន បានអធិប្បាយពីអ្វីដែលគាត់រៀនជាមួយសហគមន៍ដោយចូលរួមនៅក្នុងសកម្មភាពនៃគំរោង និង ពីរបៀបដែលគាត់ " មានអារម្មណ៏ថាមានការជិតស្និទ្ធជាមួយអ្នកនេសាទដោយគាត់សង្កេតឃើញមានការផ្លាស់ប្ដូរការគិតរបស់ពួកគេ តាមរបៀបដែលពួកគេមានប្រតិកម្មលើបញ្ហាដែលទាក់ទងវិស័យជលផល "។ អត្ថបទរបស់កញ្ញា Elizabeth M Gonzales នៃប្រទេសហ្វីលីពីន បានចងក្រងពីការណែនាំឱ្យដឹងពីរបៀបធ្វើការជាមួយសមាជិកសហគមន៍លើ " យុទ្ធសាស្រ្តជំរើសអភិវឌ្ឍន៏ដើម្បីបង្កើនការចូលរួម....ក្នុងអភិបាលកិច្ចមូលដ្ឋាន "។ នាងក៏បានណែនាំយើងឱ្យស្គាល់លោក Manuel Puzon ជាអ្នកនេសាទដែលបានអភិវឌ្ឍន៏សមត្ថភាពដឹកនាំរបស់គាត់ ហើយក្លាយជាសមាជិកនៃក្រុមគ្រូបំពាក់បំប៉នមូលដ្ឋាន ដើម្បីរៀបចំសិក្ខាសាលាបំពាក់បំប៉នអ្នកនេសាទ "។

អត្ថបទទី៣ សរសេរដោយ B K Sahay, K P Singh និង S N Pandeya គឺអំពី ក្រុមជួយខ្លួនឯង ក្នុងរដ្ឋ Jharkhand នៃប្រទេសឥណ្ឌា ពីរបៀបដែលពួកគេចាប់ផ្ដើម និង របៀបដែលពួកគេប្រមូលផ្ដុំគ្នាដើម្បីដោះស្រាយជំលោះទាក់ទងនឹងមនុស្សម្នាក់ៗដែលព្យាយាមទាមទារកម្មសិទ្ធលើស្រះសហគមន៏របស់ពួកគេ។ អត្ថបទដែលបានផ្ដល់មកឱ្យ STREAM មកពីទ្វីបអាព្រិចលើកដំបូងគឺ Yemi Akegbejo-Samsons បានរាយការណ៏ពីការសិក្សាដែលពិនិត្យមើលពីការជះឥទ្ធិពលនៃកសិកម្មនៅទីក្រុងលើបរិស្ថានដែសមុទ្រ និង ភាពជាក់ស្ដែងនៃការប្រើប្រាស់ទឹក នៅក្នុងរដ្ឋ Ondo នៃប្រទេសនីហ្សេរីយ៉ា។

អត្ថបទពីរចុងក្រោយមកពីប្រទេសវៀតណាម បន្តពីទស្សនាវដ្ដីលេខ(៤) ពិសេស លើការវិភាគការចិញ្ចឹមជីវិតដោយមានការចូលរួម។ *Pham Minh Tam និង Trinh Quang Tu* សរសេរពីអ្វីដែលពួកគេបានរៀនតាមរយៈបទពិសោធន៏នៃការវិភាគការចិញ្ចឹមជីវិតដោយប្រើការវាយតំលៃជនបទដោយមានការចូលរួម។ *Nguyen Van Tu និង Nguyen Minh Duc* ភ្ជាប់ការប្រើប្រាស់យុទ្ធសាស្រ្តចិញ្ចឹមជីវិតដោយនិរន្តរភាព ក្នុងការអនុវត្តន៏គំរោង ដែលមានគោលបំណងលើកកំពស់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅតំបន់ជនបទតាមរយៈការគ្រប់គ្រងធនធានវារីជាតដោយនិរន្តរភាព។

សូមលោកអ្នកអានដោយក្ដីរីករាយ

លោក Graham Haylor នាយកគំរោង STREAM

លោក William Savage បណ្ណាធិការទស្សនាវដ្ដី STREAM

# **រៀនឱ្យកាន់តែស៊ីជំរៅពីគំរោងគ្រប់គ្រងធនធានជលផល**

*Tee-Jay A San Diego*

## **គំរោងគ្រប់គ្រងធនធានជលផល** (FRMP) **និង ការិយាល័យជលផល និង ធនធានវារីជាត** (BFAR)

គំរោងគ្រប់គ្រងធនធានជលផលនៃការិយាល័យជលផល និង ធនធានវារីជាតនៃប្រទេសហ្វីលីពីន បានអនុវត្តគំរោងរបស់ខ្លួនពីឆ្នាំ ១៩៩៨-២០០៤។ ទិសដៅអភិវឌ្ឍន៍របស់គំរោងគឺ ទប់ស្កាត់ភាពរិចរិលនៃធនធានជលផល និង កាត់បន្ថយភាពក្រីក្រនៅតំបន់ឆ្នេរ និង លើកកំពស់ស្ថានភាពសង្គមតាមរយៈផ្នែក៣ នៃគំរោងគ្រប់គ្រងធនធានជលផល ការរកប្រាក់ចំណូលមកពីប្រភពផ្សេងៗ និង ការកសាងសមត្ថភាព។ FRMPត្រូវបានអនុវត្តទូទាំងប្រទេស នៅក្នុងឆកចំនួន ១៨ ក្នុងក្រុងចំនួន ១០០ គ្រប់គ្រងដោយ ការិយាល័យគ្រប់គ្រងគំរោង (PMO) ហើយដឹកនាំដោយ នាយកគំរោង។

ក្នុងតំបន់៦ (ភាគខាងលិច Visayas) តំបន់គំរោងគឺនៅឆក Sapian ដែលមានភូមិចំនួន ១៥ ក្នុងក្រុង៣: ក្រុង Batan ក្នុងខេត្ត Aklan និង Ivisan និង Sapian ក្នុងខេត្ត Capiz។ គំរោងក៏រាប់បញ្ចូលខេត្តទាំងពីរ និង រដ្ឋបាលមូលដ្ឋាន៣ ជាអ្នកចូលរួមអនុវត្តគំរោង។ នៅថ្នាក់តំបន់ ផ្នែកអនុវត្តគំរោង (PIU) រួមមាន បុគ្គលិករបស់ BFAR ៦ នាក់ ហើយដឹកនាំដោយ អ្នកសំរបសំរួល គំរោងថ្នាក់តំបន់ម្នាក់ ដែលរៀបចំធ្វើផែនការ ការអនុវត្តន៍ និង ធ្វើការត្រួតពិនិត្យ និង វាយតំលៃ។

## **បទពិសោធន៏របស់សមាជិកផ្នែកអនុវត្តគំរោង** (PIU)

### *សិក្ខាសាលាធ្វើផែនការ*

បន្ទាប់ពីរៀនចប់មហាវិទ្យាល័យ ខ្ញុំធ្វើជាបុគ្គលិកបច្ចេកទេសឱ្យ FRMP ជាកន្លែងដែលខ្ញុំរៀនពីវិធីសាស្រ្តចូលរួមក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ។ សកម្មភាពទី១ ដែលខ្ញុំបានចូលរួមគឺ សិក្ខាសាលាធ្វើផែនការដែលចូលរួមដោយអ្នកអនុវត្តគំរោងមកពី PMO, PIU ខេត្ត Aklan និង Ivisan និង ផ្នែកគ្រប់គ្រងជលផលក្រុង Batan, Ivisan និង Sapian។ លទ្ធផលនៃសិក្ខាសាលាត្រូវបានយកមកធ្វើជាគោលការណ៏ណែនាំក្នុងការអនុវត្តន៏សំរាប់ឆ្នាំនោះ។ តាមរយៈបទពិសោន៏នេះ ខ្ញុំមានការយល់ដឹងកាន់តែច្រើនពីរចនាសម្ព័ន្ធរបស់គំរោង ជួបជាមួយអ្នកដែលពាក់ពន្ធ័ និង រៀនពីសារៈសំខាន់នៃការសំរបសំរួល ការចូលរួមយ៉ាងសកម្មនៃវិស័យដែលទាក់ទង និង ចែករំលែកនូវបទពិសោធន៏ក្នុងដំណើរការធ្វើផែនការ។

### *ការវាយតំលៃធនធានតំបន់ឆ្នេរដោយមានការចូលរួម*



អ្នកសំរបសំរួល និង អ្នកចូលរួម PCRA ចុះអនុវត្តនៅតំបន់ព្រៃកោងកាងក្នុងភូមិ Bilao ក្រុង Sapian ខេត្ត Capiz

បទពិសោធន៏លើកដំបូងរបស់ខ្ញុំអំពីគំរោងគឺ ការវាយតំលៃធនធានតំបន់ឆ្នេរដោយមានការចូលរួម (PCRA) នៃគំរោង FRMP ក្នុងភូមិ៣នៃខេត្ត Ivasian។ អ្នកដឹកនាំអ្នកនេសាទដែលបានជ្រើសរើស បានចូលរួមក្នុង PCRA ដែលរួមមានការបង្រៀនពីប្រពន្ធ័អេកូឡូស៊ីរបស់តំបន់ឆ្នេរ សិក្ខាសាលា និង ការអនុវត្តន៏។ អ្នកចូលរួមត្រូវបានគេស្នើរឱ្យដាក់នៅលើផែនទីភូមិរបស់ខ្លួន ពីលក្ខណៈជីវ-រូប (ឧទាហរណ៏ៈ ឆ្នេរខ្សាច់ ច្រាំងថ្ម) ធនធាន ការប្រើប្រាស់ បញ្ហា និង ការជះឥទ្ធិពលដែលកើតមាននៅក្នុងភូមិរបស់ពួកគេ។ ការចុះអនុវត្តន៏ត្រូវបានធ្វើនៅតំបន់ព្រៃ

កោងកាងដើម្បីវាយតំលៃស្ថានភាពបច្ចុប្បន្ននៃប្រពន្ធ័អេកូឡូស៊ី និង ដើម្បីវាយតំលៃផែនទីធនធានដែលបានគូរក្នុងកំឡុងពេលធ្វើសិក្ខាសាលា។ សកម្មភាពស្រដៀងគ្នានេះដែរក៏បានធ្វើនៅក្នុងភូមិ៣ នៃក្រុង Batan និង ភូមិ ៩ នៃក្រុង Sapian ពេញមួយឆ្នាំ។ តាមរយៈដំណើរការ អ្នកនេសាទបានយល់ពីស្ថានភាពសង្គម ដែលជះឥទ្ធិពលលើបរិស្ថានតំបន់ឆ្នេរ និង សមុទ្រ។ ជាអ្នកសំរប-សំរួលក្នុងសកម្មភាពនេះ ខ្ញុំដឹងពីសារៈសំខាន់របស់អ្នកពាក់ពន្ធ័យល់ដឹងពីស្ថានភាពបច្ចុប្បន្ននៅក្នុងតំបន់ ក្នុងការអនុវត្តន៏គំរោង។

*ជំរកត្រី*

ខ្ញុំក៏ជាអ្នកបង្កើតទីជំរកត្រី និង កន្លែងបំរុងទុកដែលស្ថិតនៅតំបន់ផ្កាថ្ម Pito ក្នុងភូមិ Mambuquiao ក្រុង Batan ខេត្ត Aklan។ យើងបានថតទុកនូវទីតាំងចំនុចនៃទីជំរកដោយប្រើប្រាស់ប្រពន្ធ័ទីតាំងពិភពលោក (GPS) ដើម្បីកំណត់ផ្ទៃក្រលាសរុប និង ទីតាំង នៅលើផែនទី។ យើងបានពិគ្រោះជាមួយអ្នកភូមិ Mambuquioa ពីសារៈសំខាន់នៃទីជំរកត្រី គំនិតជាមូលដ្ឋាន និង ផែនការគ្រប់ គ្រង។ ភាគច្រើននៃអ្នកភូមិមានការពេញចិត្តចំពោះសំណើរនេះដោយសារពួកគេបានដឹងពីផលប្រយោជន៏របស់វារួចទៅហើយ។ លើកលែងតែម្ចាស់ឧបករណ៏នេសាទដែលស្ថិតនៅក្នុងតំបន់នោះដែលប្រឆាំងនឹងសំណើរនេះ ដោយសារគេដឹងថានៅពេលដែល ទីជំរកត្រីត្រូវបានបង្កើត ឧបករណ៏នេសាទរបស់គេនឹងត្រូវគេយកចេញ។ បន្ទាប់ពីមានការពិគ្រោះយោបល់ មន្ត្រីភូមិបានព្រាង សំណើរមួយទៅរដ្ឋបាលក្រុងដើម្បីអនុម័តលើសំណើរ។ ដោយមានការជួយគាំទ្រពីក្រុមប្រឹក្សាក្រុង និង សហគមន៏នៅទីបញ្ចប់ សំណើរត្រូវបានអនុម័ត និង ទីជំរកត្រីត្រូវបានបង្កើត។ នៅពេលបច្ចុប្បន្ន យើងសង្កេតឃើញមានការផ្លាស់ប្តូរជាវិជ្ជមាន ដោយប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ចមានឡើងវិញ និង ផលត្រីចាប់បានមានការកើនឡើង។

*មជ្ឈមណ្ឌលធនធានរៀនសូត្រភូមិ* (BLRC)

ការទទួលខុសត្រូវរបស់ខ្ញុំមួយទៀតគឺសកម្មភាព ពត៌មាន អប់រំ និង ទំនាក់ទំនង (IEC) របស់គំរោង។ ក្រោមផ្នែកគ្រប់គ្រងធន ធានជលផល IEC មានគោលបំណងនាំសារដល់អ្នកពាក់ពន្ធ័ពី ការអភិរក្ស ការការពារ និង ការគ្រប់គ្រងធនធាននៅតំបន់ឆក។ សកម្មភាពសំខាន់ៗដែលគំរោង FRMP ចាប់ផ្តើមនៅឆក Sapian គឺបង្កើតមជ្ឈមណ្ឌលធនធានរៀនសូត្រភូមិ (BLRC)។ BLRC នឹងក្លាយទៅជាឃ្លាំងនៃពត៌មាន និង ទីកន្លែងពិភាក្សា កន្លែងបញ្ចាំងកុន និយាយរឿងនិទាន បង្រៀន និង សិក្ខាសាលា។ អ្នកថែទាំ BLRC ត្រូវបានជ្រើសរើសដើម្បីទទួលខុសត្រូវរាល់សកម្មភាពនៅមជ្ឈមណ្ឌល។ ឥឡូវនេះ មាន BLRC ៣ ត្រូវបាន បង្កើតបន្ថែម។

*ការកសាងសមត្ថភាព*

FRMP ក៏មានកម្មវិធីកសាងសមត្ថភាពជាមួយអង្គការប្រជាជន និង សហករណ៏ដែលបង្កើតឡើងដោយអ្នករៀបចំសហគមន៏។ សកម្មភាពបំពាក់បំប៉នសំខាន់ៗរួមមាន:

- ការបង្កើតថ្នាលបណ្តុះកូនព្រៃកោងកាង និង ការគ្រប់គ្រងការដាំកូនឈើក្នុងភូមិ Napti និង Cabugao
- ទស្សនៈកិច្ចរបស់ប្រធានសហគមន៏ទៅកាន់គំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរដែលទទួលបានជោគជ័យ នៅក្នុងតំបន់
- បង្រៀនពីច្បាប់ជលផលឆ្នាំ ១៩៩៨ របស់ប្រទេសហ្វីលីពីន

តាមរយៈការចូលរួមរបស់ខ្ញុំនៅក្នុងសកម្មភាពនេះ ខ្ញុំមានអារម្មណ៏ថា កាន់តែមានការជិតស្និទជាមួយអ្នកនេសាទ ដោយសារតែខ្ញុំសង្កេតឃើញមានការផ្លាស់ប្តូរនៅក្នុងការគិតរបស់ពួកគេ តាមរយៈរបៀបដែលគេប្រតិកម្មទៅនឹងបញ្ហាទាក់ទងនឹងការនេសាទ ។

*ការយល់ឃើញផ្ទាល់ខ្លួន*

មានគំរោងជាច្រើនបានធ្វើដោយមានទិសដៅដូចគំរោង FRMP ក្នុងឆក Sapian ។ សហគមន៏នៅតំបន់ឆ្នេរ និង មន្ត្រីមូលដ្ឋានចង់ឃើញនូវលទ្ធផលជាក់ស្តែងរបស់គំរោង ដូចជា គំរោងការចិញ្ចឹមជីវិត ប៉ុន្តែមានការរុញរាអំពីគំរោងអភិវឌ្ឍន៏ដូចជា FRMP ។ តាមរយៈការពន្យល់ជាទៀតទាត់ និង យុទ្ធនាការ IEC ជាបណ្តើរៗប្រជាជនបានដឹងថា ជោគជ័យអាចទទួលបានតាមរយៈដំណើរការជាជំហានៗ ។

ការជះឥទ្ធិពលរបស់គំរោងមិនត្រឹមតែលើការលើកកំពស់អ្វីដែលមើលឃើញជាក់ស្តែង ដូចជាគំរោងបង្កើនប្រាក់ចំណូល និង អភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែលើការយល់ដឹងរបស់សហគមន៏ និង អាជ្ញាធរមូលដ្ឋានពីតួនាទីដ៏សំខាន់របស់ពួកគេក្នុងការគ្រប់គ្រងធនធានវារីជាត ។ លើកកំពស់ការយល់ដឹងពីសិទ្ធ និង ការទទួលខុសត្រូវរបស់ពួកគេ នឹងរួមចំណែកដល់គំរោង និង ជាសន្ទស្សន៏មួយនៃជោគជ័យរបស់គំរោង FRMP ។

*Tee-Jay A San Diego*គឺជាបុគ្គលិកបច្ចេកទេសរបស់ BFAR 6 នៃផ្នែកអនុវត្តគំរោង FRMP ។
យើងអាចទាក់ទងតាមរយៈ < frmp6@skyinet.net >

## ការណែនាំឱ្យដឹងពីយុទ្ធសាស្ត្រ *SIAD* និង ការធ្វើផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានដោយមានការចូលរួម

*Elizabeth M Gonzales*

### *អភិវឌ្ឍន៍តំបន់ចំរុះដោយនិរន្តរភាព* (SIAD)

អភិវឌ្ឍន៍តំបន់ចំរុះដោយនិរន្តរភាពគឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍មួយ ដែលបង្កើតឡើងដើម្បីបង្កើនការចូលរួមរបស់សមាជិកសហគមន៍ក្នុងការគ្រប់គ្រងមូលដ្ឋាន។ វាជាកម្មវិធីគំរូមួយ " ដៃគូរដើម្បីអភិវឌ្ឍន៍ធនធានមនុស្សក្នុងតំបន់ជនបទរបស់ប្រទេសហ្វីលីពីន (PhilDHRRA) " ដែលជាលេខាធិការនៃបណ្តាញអង្គការមិនមែនរដ្ឋាភិបាលជាតិ។ ជាយុទ្ធសាស្ត្រ បង្កើតឡើងចេញពីគំនិតនៃការអភិវឌ្ឍន៍ដោយនិរន្តរភាព និង ការផ្តល់អំណាចឱ្យប្រជាជន។ យើងបានផ្តោតលើសហគមន៍ SIAD ដែលជ្រើសរើសដោយសមាជិករបស់ PhilDHRRA ដើម្បីអភិវឌ្ឍន៍ និង ពង្រឹងតំបន់ឆ្នេរ វាលទំនាប និង ខ្ពង់រាប។ ទីប្រជុំជនមួយត្រូវបានគេជ្រើសរើសដើម្បីជាឯកតាផែនការមូលដ្ឋាមមួយដើម្បីជ្រើសរើសតំបន់គំរូ។

ផ្នែកសំខាន់នៃយុទ្ធសាស្ត្រ PhilDHRRA, SIAD រួមមាន ស្ថានភាពទូទៅនៃតំបន់ និង ផែនការ ការកសាងសមត្ថភាព កម្មវិធីសំរបសំរួល និង ដៃគូរ ការប្រើប្រាស់ធនធានសំរាប់រៀបចំសហគមន៍ ការលើកកំពស់សិទ្ធិលើធនធាន និង ការអភិវឌ្ឍន៍ប្រពន្ធ័ផលិតភាព។ ការអនុវត្តន៍របស់ SIAD ត្រូវបានបំពេញដោយកម្មវិធី PhilDHRRA និង សេវាកម្មសមាជិក។

### *ទីកន្លែងដែលបានស្នើរ*

Barotac Viejo ស្ថិតក្នុងក្រុង Iloilo គឺជាទីប្រជុំជនក្នុងចំណាត់ថ្នាក់ទី ៣[៧] ស្ថិតនៅភាគខាងជើងទីក្រុង Iloilo បើកបរដោយរថយន្តប្រហែល ២ ម៉ោង។ វាមានតំបន់ឆ្នេរ វាលទំនាប និង ខ្ពង់រាប ដែលតំរូវទៅតាមលក្ខខ័ណ្ឌរបស់ SIAD។ វាក៏ជាទីតាំងរបស់គំរោងដែលមានឈ្មោះថា " ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានឆ្ពោះទៅរកការកែទំរង់ដីធ្លី និង ការអភិវឌ្ឍន៍កសិកម្ម (PATANOM) "។ PATANOM គឺជាសហពន្ធ័នៃអង្គការប្រជាជន ជាអ្នកអនុវត្តគំរោងដោយមានការជួយឧបត្ថម្ភពី PhilDHRRA។ PATANOM បានបង្កើតអង្គការសង្គមស៊ីវិលដើម្បីដឹកនាំគំរោង។ អនុសារណៈនៃការយោគយល់គ្នារវាងអាជ្ញាធរមូលដ្ឋាន និង PATANOM មានរួចទៅហើយ ហើយ Barotac Viejo គឺគ្រាន់តែជាទីតាំងគំរូមួយរបស់កម្មវិធី SIAD ប៉ុណ្ណោះ។

### *ការណែនាំឱ្យដឹង*

ជាផ្នែកមួយនៃសកម្មភាពកសាងសមត្ថភាព ការណែនាំឱ្យដឹងពី SIAD ត្រូវបានធ្វើក្នុងខែវិច្ឆិកា ២០០២ នៅសាលាក្រុង Barotac Viejo។ អ្នកចូលរួមមាន ៣៥ នាក់ដែលមានតំណាងមកពី កសិករ អ្នកនេសាទ ជនជាតិភាគតិច ស្ត្រី អ្នកបើកបរតាក់ស៊ី និង ម៉ូតូកង់៣ បានចូលរួមនៅក្នុងការណែនាំនេះ។ អ្នកចូលរួមទាំងអស់ត្រូវបាន



លោក Manuel Puzon ស្ថិតនៅខាងឆ្វេងដៃក្នុងពេលធ្វើការវាយតំលៃរបស់ SIAD នៅ Inopacan

---

[៧] ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃទីប្រជុំជនដែលមានប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំពី ២១-២៧ លានប៉េសូ (៤២០,០០០-៥៤០,០០០ ដុល្លាអាមេរិច)

លើកទឹកចិត្តឱ្យណែនាំខ្លួនឯង និង ពិនិត្យមើលលើក្ដីរំពឹងទុក។ លោក Josephine Savaris ជាអ្នកសំរបសំរួលកម្មវិធី PhilDHRRA បានបង្រៀនអំពី SIAD ។ អ្នកចូលរួមត្រូវបានគេបង្រៀនឱ្យដឹងពីនិយមន័យ គំនិត គោលការណ៍ និង ចរិតលក្ខណៈរបស់ SIAD ។

*សក្ខីភាព*

ឯកសារវីដេអូ ដែលមានចំណងជើងថា " ទីក្រុងនិយាយ " បានបង្ហាញពីបទពិសោធន៍របស់ SIAD ពីឆ្នាំ ១៩៩៤-២០០១ នៅទីតាំងសាកល្បង Inopacan, Leyte ។ វាបានកត់ត្រាទុកនូវរឿងពិតនៃតំណាងក្រុមពហុវិស័យ ពីអ្វីដែល SIAD ជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ពួកគេ។ រឿងពិតដែលសំខាន់មួយគឺលើលោក Manuel Puzon ជាអ្នកនេសាទទើបតែរៀនចប់បឋមសិក្សាហើយចាប់ផ្ដើមធ្វើជាសមាជិកនៃអង្គការអ្នកនេសាទ ហើយដែលយើងសង្កេតឃើញថាស្ងាត់ស្ងៀមក្នុងពេលប្រជុំ។ នៅពេលដែលសកម្មភាពរបស់ SIADកាន់តែមានដំណើរការទៅមុខ គាត់បន្ដិចម្ដងៗអភិវឌ្ឍន៏សមត្ថភាពដឹកនាំរបស់គាត់លេចធ្លោក្នុងចំណោមមិត្តភក្ដិរបស់គាត់។ លោក Manuelត្រូវបានជ្រើសរើសជាអនុប្រធានអង្គការរបស់គាត់ ហើយក្លាយទៅជាសមាជិកនៃក្រុមគ្រូបំពាក់បំប៉នមូលដ្ឋាន ដើម្បីរៀបចំសិក្ខាសាលាបំពាក់បំប៉នអ្នកនេសាទ ។ ឥឡូវនេះគាត់ត្រូវបានក្រុង ឱ្យធ្វើការងាររៀបចំសហគមន៏ក្នុងភូមិដ៏ទៃទៀតនៃក្រុង។

*ធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋានដោយមានការចូលរួម (PLDP)*

ការបង្រៀននៅពេលល្ងាចចាប់ផ្ដើមរៀនពី PLDP ជាទំរង់ (Framework)មួយដែលបញ្ជាក់ពីសំណើរសំរាប់ណែនាំការអភិវឌ្ឍន៍នៅតំបន់ជាក់លាក់ណាមួយ។ ផែនការប្រើប្រាស់ដីដ៏ទូលំទូលាយ (CLUP)ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋានគឺជាឧទាហរណ៏ស្រាប់។ ដោយសារ CLUPត្រូវបានបង្កើតរួចទៅហើយ វាជាចំណុចចាប់ផ្ដើមដែលប្រើប្រាស់ដោយ PhilDHRRA ដើម្បីអនុវត្ត SIADនៅតំបន់សាកល្បង Inopacan។ ឯកសារវីដេអូ " ជំហានអង់អាចឆ្ពោះទៅរកការអភិវឌ្ឍន៏តំបន់ចំរុះដោយនិរន្តរភាព " បានបង្ហាញអំពីសកម្មភាពរបស់ PLDP នៅ Inopacan។ វាបង្ហាញពីដំណើរការតាមពេលវេលា សំរបសំរួលដោយ PhilDHRRA ដែលបានជាលទ្ធផលនៃការបង្កើត CLUP មានរយៈពេល ៣០ ឆ្នាំសំរាប់ Inopacan។ វាជាសក្ខីភាពមួយបង្ហាញពីសហប្រតិបត្តិការ និង កិច្ចខិតខំរបស់អាជ្ញាធរមូលដ្ឋាន អង្គការ និង ភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង អង្គការប្រជាជនដែលសំរេចបាននូវការលូតលាស់ដែលមាននិរន្តរភាពបែបនេះ។

*តំណាងពីមូលដ្ឋាន (LSR)*

សកម្មភាពចុងក្រោយគឺការពិភាក្សាដែលមានតំណាងមកពីមូលដ្ឋាន (LRS)៖ ធ្វើការគ្រប់គ្រងដោយមានការចូលរួមឱ្យក្លាយជាការពិត។ LRSត្រូវបានគេឱ្យធ្វើជាតំណាងនៅក្នុងច្បាប់គ្រប់គ្រងមូលដ្ឋាន ឆ្នាំ ១៩៩១។ ដោយសារគ្មានដំណើរការបោះឆ្នោតច្បាស់លាស់ វាមិនត្រូវបានគេយកមកអនុវត្តនៅថ្នាក់មូលដ្ឋាន។ សម្ព័នមិត្រនៅក្នុងសភាតំណាងរាស្ត្រ និង ព្រឹទ្ធសភាជាអ្នកជាអ្នកឧបត្ថម្ភសេចក្ដីព្រាងច្បាប់ស្ដីពី *LSR*។ ប៉ុន្ដែដើម្បីបង្កើនល្បឿននៃការអនុម័តលើសេចក្ដីព្រាង យុទ្ធនាការរកហត្ថលេខាត្រូវបានធ្វើដោយអង្គការមិនមែនរដ្ឋាភិបាលនៅទូទាំងប្រទេស។

នៅក្នុងសេចក្តីថ្លែងការណ៏របស់នាង *Josephine Savaris* បានសង្កត់ធ្ងន់ថា យុទ្ធសាស្ត្ររបស់ *SIAD* ទទួលស្គាល់ពីសារៈសំខាន់នៃសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ដោយសារគេមានអំណាចខាងច្បាប់បង្កើតសំណើរគំរោងដែលអភិវឌ្ឍន៏ដោយវិស័យផ្សេងៗនៅក្នុងក្រុង ។

**ការតាមដាន** (Follow-up)

ជាសកម្មភាពតាមដាន វគ្គបំពាក់បំប៉នពីស្តីពីការវាយតំលៃជនបទដោយមានការចូលរួម ត្រូវបានធ្វើនៅក្នុងខែមិនា ២០០៣ ។ មនុស្ស ៥ នាក់ត្រូវបានគេជ្រើសរើសចេញមកពីភូមិនិមួយៗ ក្នុងចំណោមភូមិ២៦ ឱ្យចូលរួមវគ្គបំពាក់បំប៉ន២ នេះ ។ ពួកគេនឹងក្លាយទៅជាអ្នកស្រាវជ្រាវនៅមូលដ្ឋាននៃភូមិរបស់ពួកគេ ។ ភាគច្រើននៃអ្នកចូលរួមគឺជាមន្ត្រីសុខាភិបាលភូមិ អ្នកជំនាញខាងជីវជាតិ និង មន្ត្រីបំរើសេវាកម្ម ដែលងាយនឹងបំពាក់បំប៉នក្នុងការប្រមូលទិន្នន័យ ។ បច្ចុប្បន្ននេះ សកម្មភាពប្រមូលទិន្នន័យកំពុងតែធ្វើនៅក្នុងភូមិទាំងអស់ ។ នៅពេលការប្រមូលទិន្នន័យត្រូវបានបញ្ចប់ *PATANOM* មានផែនការជួលអ្នកវិភាគទិន្នន័យដើម្បីជួយ និង បំពាក់បំប៉នអ្នកស្រាវជ្រាវមូលដ្ឋានដើម្បីវិភាគទិន្នន័យ ។

ទាក់ទងនឹងតំណាងពីមូលដ្ឋាន ច្បាប់ចំលងស្តីពី "អំពាវនាវឱ្យមានសកម្មភាព " ដែលចុះហត្ថលេខាដោយប្រធានអង្គការប្រជាជនទូទាំងប្រទេស ត្រូវបានបញ្ជូនទៅសមាជិកព្រឹទ្ធសភាម្នាក់ៗឱ្យទាន់ពេល នៅពេលបើកសមាជ ក្នុងខែមេសា ២០០៣ ។

*Elizabeth M Gonzales* គឺជាអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងរបស់គំរោង STREAM នៅប្រទេសហ្វីលីពីន យើងអាចទាក់ទងតាមរយៈ < streambfar-phil@skyinet.net >

ចង់ដឹងបន្ថែមពី SIAD និង " ការផ្លាស់ប្តូរសំខាន់ " របស់លោក Manuel Puzon សូមទាក់ទង Josephine Savaris < phildvissect@pacific.net.ph >

# ការកសាងក្រុម ជោគជ័យនៃផលិតកម្ម និង ការព្យាយាមដើម្បីការពារនូវការចាប់យកធនធាន

*B K Sahay, K P Singh និង S N Pandeya*

## ការចាប់ផ្ដើមដំបូង

សកម្មភាពរបស់គំរោង KRIBP-E[2] លើការសំអាតស្រះ កំចាត់ស្មៅចង្រៃ និង ប្រើប្រាស់កំបោរបានចាប់ផ្ដើមនៅឆ្នាំ ១៩៩៦ ក្នុងរដ្ឋ Bihar ហើយឥឡូវនេះគឺរដ្ឋ Jharkhand ។ ស្រះរបស់សហគមន៍ដែលមានទំហំប្រហែល ៨០០ ម$^{២}$ គឺជាកម្មសិទ្ធរបស់អ្នក ភូមិ និង ប្រើប្រាស់សំរាប់ងូតទឹក លាងសំអាតសត្វពាហនៈ និង ស្រោចស្រព។ មុនឆ្នាំ ១៩៩៦ គ្មានការចិញ្ចឹមត្រីទេ។ បន្ទាប់មក ក្រុមក្មេងជំនាន់ក្រោយ (ក្រុមជួយខ្លួនឯង) ជាមួយសមាជិកទាំង៣៦ គ្រួសារ បានចាប់ផ្ដើមធ្វើវារីវប្បកម្ម។ គេទទួលការបំពាក់ បំប៉នពី KRIBP-E ហើយនៅខែមិថុនា គេដាក់កូនត្រីបានមកពី SRI [3]ចំនួន ១ ម៉ឺនក្បាលដែលមានទំហំ ៣ ស.ម។ អ្នកភូមិបាន អភិវឌ្ឍន៍កាលវិភាគ អ្វីដែលគេត្រូវការពីគំរោង អ្វីដែលអាចផ្ដល់ឱ្យបាន ហើយនរណាជាអ្នកធ្វើអ្វី។ ក្រុមក៏បានសំរេចពីតួនាទី និង ការទទួលខុសត្រូវរបស់សមាជិក សំរាប់ការផ្ដល់ចំណី ពិនិត្យមើល និង ការគ្រប់គ្រងផ្សេងៗទៀត។ អ្នកភូមិបានដាក់អាចម៍គោ ដោយកញ្ច្រែង ដែលមានទំងន់ពី ៦០-៧០ គ.ក ក្នុងមួយសប្ដាហ៍។ គំរោងផ្ដល់ឱ្យនូវកំបោរ កន្ទក់ និង ជីគីមីដើម្បីបំប៉ន និង ព្រលែងទៅក្នុងស្រះ។

## លទ្ធផល



ក្រុមប្រមូលផលដោយជោគជ័យ

ក្នុងឆ្នាំ ១៩៩៦ គ្មានប្រពន្ធ័បង្ហូរទឹកចេញត្រឹមត្រូវ ហើយក្រុមមិនទទួលបានផលល្អទេ។ គេប្រមូលផលនៅខែមិនា ហើយទទួលបានប្រាក់ ៦ ពាន់រូពី។ គេគ្មានមងធំ និង ការបំពាក់បំប៉នទេ។ គេជួលមងពីភូមិផ្សេងទៀត ដោយតំលៃ ២០០ រូពី។ ក្នុងឆ្នាំ ១៩៩៧ សហគមន៍នៅតែបន្តចិញ្ចឹម ដោយបន្ថែមកូនត្រី ២ គ.ក ដែលទិញពីផ្សារក្នុងភូមិ។ ការទទួលផលបានគ្រាន់បើជាងមុន ដោយលក់ត្រីបាន ៩ ពាន់រូពី ហើយត្រីខ្លះមានទំងន់រហូតដល់ ៣-៣.៥ គ.ក។ នៅពេលនោះពួកគេខ្ចីមងពីសកលវិទ្យាល័យកសិកម្ម Birsa។ ពួកគេព្យាយាមពិនិត្យមើលត្រីដែលចេញក្រៅដោយធ្វើបន្ទះឬស្សីរាំង។ ប៉ុន្តែដោយសារភ្លៀងខ្លាំងពួកគេមិនអាចទទួលបានជោគជ័យដូចក្នុងឆ្នាំ ១៩៩៦ ដោយបាត់បង់ត្រីជាច្រើន។ ដោយមានការជួយឧបត្ថម្ភពីគំរោង GVT ក្នុងឆ្នាំ ១៩៩៨ ប្រពន្ធ័បង្ហូរទឹកចេញត្រូវបានសាងសង់ដោយចំណាយអស់ ៦ ម៉ឺនរូពី។ សមាជិកសហគមន៍បានផ្ដល់កំលាំងពលកម្មប្រហែល ៥០% នៃតំលៃពលកម្មសរុប។

នៅពេលនេះ សហគមន៍ និង Jankars[4] បានទទួលការបំពាក់បំប៉នជាច្រើនពីគំរោង ហើយចំណេះដឹងរបស់គេត្រូវបាន

---

[2] ជាគំរោងនៅភាគខាងកើតប្រទេសឥណ្ឌាដែលផ្ដល់មូលនិធិដោយ DFID ហើយឥឡូវនេះមានឈ្មោះថា Gramin Vikas Trust ឬ GVT

[3] សង្គមសំរាប់ឧស្សាហូបនីយកម្មជនបទ (Society for Rural Industrialisation)

[4] សមាជិកសហគមន៍ដែលបំពាក់បំប៉នដោយ GVT ដើម្បីឱ្យក្លាយជាអ្នកជំនាញក្នុងភូមិ

អភិវឌ្ឍន៍ជាលំដាប់។ ក្រុមសន្សំមានប្រាក់ប្រហែល ១៨,០០០ រូពី (១២,០០០រូពី ដាក់នៅក្នុងធនាគារដោយការប្រាក់ ១២% ក្នុងមួយឆ្នាំ ហើយ ៦,០០០ រូពី ជាប្រាក់ឥណទានដែលមានការប្រាក់ ៥% ក្នុងមួយខែ)។ អត្រាការប្រាក់នៅក្នុងភូមិគឺ ១០% ក្នុងមួយខែ។ លើផ្នែកទីផ្សារ បើសិនជាក្រុមប្រមូលផលបាន ៣០-៤០ គ.ក ពួកគេនឹងលក់ក្នុងចំណោមពួកគេ និង អ្នកខាងក្រៅ។ នៅពេលគេប្រមូលផលនៅខែមិនា មនុស្សជាច្រើនប្រមូលផ្ដុំមើល។ ជាតំបូងគេលក់ឱ្យក្រុមតំលៃ ៣០ រូពី បន្ទាប់មកលក់ឱ្យអ្នកជិតខាងតំលៃ ៤០ រូពី ហើយបន្ទាប់មកគឺលក់ឱ្យអ្នកខាងក្រៅ ប៉ុន្តែមិនដែលនៅសល់ត្រីទេ។

**ជំលោះ-ការទន្ទ្រានចូលដោយបុគ្គល និង ការព្យាយាមរបស់សហគមន៍**

នៅពេលដែលការសាងសង់បំពង់បង្ហូរទឹកចេញកំពុងដំណើរការសាងសង់ក្នុងឆ្នាំ ១៩៩៨ មនុស្សនៅក្នុងភូមិម្នាក់ដែលរស់នៅ Ranchi ដែលធ្វើការនៅការិយាល័យអង្កេត តំណាងឱ្យអ្នកសំរបសំរួលគំរោង GVT នៅរដ្ឋ Bihar បានអះអាងថាស្រះនេះជាកម្មសិទ្ធរបស់គាត់ផ្ទាល់ ដូច្នេះសូមបញ្ឈប់ការសាងសង់។ ប៉ុន្តែនៅពេលដែលការសាងសង់បានប្រហែល ៨០%រួចទៅហើយ។ អ្នកអះអាងត្រូវបានមន្ត្រីរបស់គំរោងស្នើរឱ្យដោះស្រាយជាមួយសហគមន៍ដោយសន្តិវិធី។ ជាមួយគ្នានេះ លិខិតអះអាងដែលគាត់បានបង្ហាញ ត្រូវបានបញ្ជូនទៅការិយាល័យទំនាក់ទំនងដើម្បីធ្វើការផ្ទៀងផ្ទាត់ពីកម្មសិទ្ធនៃដីនេះ ហើយស្នើរឱ្យមន្ត្រីផ្ដល់នូវការឆ្លើយតបមក KRIBP-E វិញ។

អ្នកអះអាងត្រូវបានគេរកឃើញថាក្លែងក្លាយ ដោយសារគ្មានការកត់ត្រានៅក្នុងបញ្ជីចំណូលសំរាប់ដីនេះ។ ជាមួយគ្នានេះ ចំណូលមិនត្រូវបានបង់ទៅឱ្យការិយាល័យទេ ដែលចាំបាច់ និង ជាឯកសារមួយដ៏សំខាន់ទាក់ទងនឹងកម្មសិទ្ធលើដីធ្លី។ អ្នកអះអាងបានត្រលប់មកកាន់ការិយាល័យជាមួយមនុស្សពីរនាក់ទៀតដើម្បីពិភាក្សារឿងរ៉ាវជាមួយអ្នកសំរបសំរួលគំរោង GVT នៅរដ្ឋ Bihar និង អ្នករៀបចំសហគមន៍ Nehalu។ ពួកគេយល់ព្រមថាគ្មានការជំទាស់លើការសាងសង់បំពង់បង្ហូរទឹកចេញដើម្បីជា ផលប្រយោជន៍របស់សហគមន៍ទេ ដូច្នេះរឿងរ៉ាវត្រូវបានបញ្ចប់។ អភិបាលស្រុកនៃរដ្ឋ Ranchi បានចុះពិនិត្យមើលស្រះនៅខែកុម្ភះ ១៩៩៨ ដើម្បីមើលសកម្មភាពចិញ្ចឹមត្រី និង យល់ព្រមឱ្យសាងសង់អាងភ្ញាស់ដែលមានតំលៃ ៦សែន រូពី ដោយលុយឱ្យតំបូងមានចំនួន ១សែន រូពីដែលនឹងទទួលនៅចុងឆ្នាំនោះ។ ពួកគេពិនិត្យមើលទីតាំងដើម្បីធ្វើផែនការ និង កន្លែងសាងសង់អាងភ្ញាស់។



ស្រះដែលមានជំលោះ- តើជាកម្មសិទ្ធរបស់អ្នកណា?

ដោយមើលឃើញជោគជ័យនៃស្រះ និង ការជួយរបស់រដ្ឋាភិបាល អ្នកអះអាងបានធ្វើការតវ៉ាជាថ្មីម្ដងទៀត។ ដូច្នេះ KRIBP-E បានស្នើរការិយាល័យទំនាក់ទំនងឱ្យធ្វើកម្មសិទ្ធឱ្យបានច្បាស់ ហើយឯកសារត្រូវបានបញ្ជូនទៅ LRDC[5] នៅ Ranchi។ អ្នកអះអាងបានព្យាយាមប្រមូលផលត្រីដោយជួលមនុស្សដែលមានមាឌធំៗ ប៉ុន្តែអ្នកភូមិបានរួបរួមគ្នា ហើយការពារគាត់មិនឱ្យប្រមូលផលត្រី។ គាត់ក៏បានប្រកាសរបាយការណ៍ស៊ើបអង្កេតក្នុងនាមសមាជិកនៃក្រុម និង ចងក្រងឯកសារប្ដឹងទៅតុលាការលើកម្មសិទ្ធស្រះ។

[5] អ្នកប្រមូលរឿងរ៉ាវទាក់ទងនឹងការកែទំរង់ដីធ្លីនៅថ្នាក់ស្រុក

ក្នុងឆ្នាំ ១៩៧០ រដ្ឋាភិបាលបានចែកចាយដីដល់ប្រជាជនដោយគ្មាននិតិវិធីត្រឹមត្រូវ ។ ឯកសាររបស់អ្នកអះអាងមានអាយុ ២៧ ឆ្នាំទៅហើយ ហើយគ្មានឯកសារនៅ LRDC ។ ឯកសារបញ្ជាក់ថាស្រះនេះគឺជាដីទំនេរ ចំណែកនៅការិយាល័យទំនាក់ទំនង ឯកសារបញ្ជាក់ថាដីនេះជាដីរបស់សហគមន៍ ដែលមិនអាចជាដីរបស់នរណាម្នាក់ឡើយ ។ ដីនេះជាដីរបស់រដ្ឋាភិបាល ។

អ្នកភូមិបានបើកអង្គប្រជុំ ហើយប្រមូលឯកសារដែលទាក់ទងនឹងកម្មសិទ្ធលើស្រះនេះ ។ រឿងរ៉ាវនេះត្រូវបានបញ្ជូនទៅ LRDC ដោយមានអនុសាសន៍ពីការិយាល័យទំនាក់ទំនងដោយចង់ឱ្យដីទៅសហគមន៍ ។ សមាជិកក្រុមទាំងអស់ក៏បានបញ្ជូនរឿងទៅ MLA[6] ក៏បានផ្តល់អនុសាសន៍ដល់ LRDC ដោយចង់ឱ្យដីទៅសហគមន៍ដែរ ដោយបញ្ជាក់ថានេះគឺជាស្រះរបស់ភូមិ ហើយមិនមែនជាកម្មសិទ្ធរបស់នរណាម្នាក់ឡើយ ។ ឥឡូវនេះសំណុំឯកសារគឺស្ថិតនៅឯតុលាការស្រុកនៅឡើយ ។ ឥឡូវនេះស្រះស្ថិតនៅក្រោមកម្មសិទរបស់សហគមន៍ ហើយនៅឆ្នាំ ២០០២ គេបានដាក់កូនត្រីចំនួន ៦ ត.ក ។

**សន្និដ្ឋាន**

ក្រុមគឺមានសាមគ្គីភាពល្អ និង មានការយល់ដឹងពីសិទ្ធរបស់ខ្លួនបានល្អ ។ ពួកគេមានផែនការយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាដែលកើតឡើង ។ នៅកនុងស្ថានភាពអាក្រក់ ពួកគេមានផែនការអភិវឌ្ឍន៍ស្រះផ្សេងទៀតដើម្បីបន្តសកម្មភាពរបស់ពួកគេ ប៉ុន្តែមិនឱ្យមិនឱ្យចំណេះដឹងខាងការចិញ្ចឹមត្រីរបស់ពួកគេបាត់បង់ឡើយ ។

B.K Sahay គឺជាអ្នកជំនាញខាងអភិវឌ្ឍន៍សង្គម Dr K P Singh អ្នកជំនាញខាងវារីវប្បកម្ម (ឥឡូវចូលនិវត្តន៍) និង S N Pandeya អ្នកជំនាញខាង ការត្រួតពិនិត្យ និង វាយតំលៃ ពីមុនជាបុគ្គលិករបស់ GVT នៅ Ranchi ។
យើងអាចទាក់ទងតាមរយៈ < rch_gvteirfp@sancharnet.in >

[6] អ្នកដែលត្រូវបានគេជ្រើសរើសឱ្យធ្វើជាតំណាងនៅមូលដ្ឋាន

## កសិកម្មនៅទីក្រុង ការប្រើប្រាស់ទឹកថ្លុងទៀត និង សេដ្ឋកិច្ចចូលធ្លាន: ករណីសិក្សា ការតាំងទីលំនៅនៅតំបន់ ដៃសមុទ្រនៃរដ្ឋ Ondo ប្រទេសនីហ្សេរីយ៉ា

*Yemi Akegbejo-Samsons*

### សេចក្តីផ្តើម និង វិធីសាស្ត្រ

ប្រហែល៤០%នៃប្រជាជនពិភពលោករស់នៅក្នុងចំងាយ ៦០ គ.ម ពីឆ្នេរសមុទ្រ។ នៅទ្វីបអាព្រិច និន្នាការកំណើនប្រជាជនបង្ហាញថាតួរលេខនេះអាចឡើងដល ៧៥% នៅក្នុងសតវត្សក្រោយ (Odada,2002)។ ដីសើមនៅតំបន់ឆ្នេរនៃអនុតំបន់សាហារ៉ា មានការផ្លាស់ប្តូរយ៉ាងខ្លាំង ដោយកំណើនប្រជាជនមកពីជនបទ និង ជនភៀសខ្លួននយោបាយ ការប្រកួតប្រជែងគ្នាដើម្បីប្រើប្រាស់ធនធានធម្មជាតិ និង ទីកន្លែងរស់នៅ ការបំពុលទ្រង់ទ្រាយធំ និង ការផ្លាស់ប្តូរដោយសារតែកំណើនសេដ្ឋកិច្ច ។

កសិកម្មនៅទីក្រុង (Urban Agriculture “UA”) ត្រូវបានគេកំណត់ថាជាឧស្សាហកម្មដែលស្ថិតនៅក្នុង ឬក៏នៅជាយក្រុង។ UA រីកលូតលាស់ ដំណើរការ និង ចែកចាយផលិតផលចំណីអាហារ និង មិនមែនចំណីអាហារផ្សេងៗ ដោយប្រើប្រាស់ធនធានមនុស្ស និង សំភារ: ផលិតផល និង សេវាកម្មដែលមាននៅក្នុង និង ជុំវិញតំបន់ទីក្រុង ហើយជាលទ្ធផលបានផ្គត់ផ្គង់ធនធានមនុស្ស និង សំភារ: ផលិតផល និង សេវាកម្មដល់តំបន់ទីក្រុងនោះវិញ។ ដោយមានកំណើនប្រជាជននៅលើពិភពលោក ការធ្វើអាជីវកម្មហួសកំរិតធនធាននៅលើដី និង ការរីកចំរើនផ្នែកបច្ចេកទេស មានការពឹងផ្អែកលើបរិស្ថានសមុទ្រកាន់តែកើនឡើង ហើយជួនកាលមានជំលោះលើការប្រើប្រាស់ ដូចជា ការផ្តល់ចំណីអាហារ ការចាក់ចោលសំរាម ដឹកជញ្ជូន និង ទំនាក់ទំនង ការទាកយករ៉ែ និង ការកំសាន្តផ្សេងៗ។

អត្ថបទនេះពិនិត្យមើលលើការជះឥទ្ធិពលនៃ UA លើបរិស្ថានដៃសមុទ្រ និង ការពិតនៃការប្រើប្រាស់ទឹកនៅក្នុងតំបន់សិក្សា។ ការសិក្សាបានធ្វើនៅតំបន់ដីសើមដៃសមុទ្រនៃរដ្ឋ Ondo ដែលមានព្រំប្រទល់ខាងកើតទល់ទន្លេ Benin ក្នុងរដ្ឋ Edo ខាងកើតទល់និងឆ្នេរសមុទ្ររដ្ឋ Ogun និង ខាងជើងទល់តំបន់រដ្ឋាភិបាល Okitipupa និង Irele។ វាស្របទៅនឹងឆ្នេរសមុទ្រ ភាគនិរតីនៃប្រទេសនីហ្សេរីយ៉ាដែលមានលក្ខណ:ជាបឹងទឹកប្រៃ និង មានជាប់នឹងទន្លេសាប។

សកម្មភាពដែលទាក់ទងនិង UA ត្រូវបានវាយតំលៃតាមរយ:ការជួបសំភាសន៍ និង បញ្ជីសំនួរដែលបានចែកចាយដល់កសិករ និង អ្នកនេសាទ ក្នុងកំឡុងពេលប្រជុំនៅតាមភូមិពីខែ កក្កដា ដល់ ធ្នូ ២០០២។ ធនធានដែលប្រើប្រាស់ដោយកសិករត្រូវបានវាយតំលៃ និង សកម្មភាពដែលទាក់ទង UAត្រូវបានរកឃើញ។ ការធ្វើនិស្សរណកម្ម (recycle)និង ការប្រើប្រាស់ទឹកឡើងវិញ (water reuse) និង វិធីសាស្ត្រត្រូវបានអង្កេត។ បញ្ហាដែលទាក់ទងនឹងការប្រើប្រាស់ទឹក និង ការប្រើប្រាស់ទឹកឡើងវិញ ត្រូវបានអង្កេត។ លក្ខណ:ទឹក (គុណភាព បរិមាណ និង ការបំពុល) ក៏ត្រូវបានវាយតំលៃតាមរយ:ការចុះពិនិត្យនៅនឹងកន្លែងដើម្បីជ្រើសរើសភូមិ និង ការវិភាគនៅមន្ទីរពិសោធដោយយកសំណាកពីភូមិផ្សេងៗ។

### លទ្ធផល

*ប្រជាជន និង ការចិញ្ចឹមជីវិតរបស់ពួកគេ*

តំបន់នេះរស់នៅដោយក្រុមជនជាតិភាគតិចសំខាន់ៗ ៣: Ilajes ដែលមានចំនួន ២ភាគ ៣ នៃប្រជាជនសរុប ជនជាតិ Ijaw Arobow និង Ijaw Apois ដែលជាក្រុមនិយាយភាសា Yoruba មានចំនួន ១ ភាគ ៣ នៃប្រជាជន។ ២៣ ភាគរយនៃបុរស និង ស្ត្រី ធ្វើនេសាទ។ សិប្បកម្មមូលដ្ឋានរួមមាន: បិទស្រា, ជាងដែក, ធ្វើមង និង ទូក។ សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរួមមាន: ធ្វើស្រែ, លក់ដូរ និង អូសទឹក។

*ផលប្រយោជន៍នៃកសិកម្មនៅទីក្រុង*

ការអនុវត្តន៏កសិកម្មនៅទីក្រុង មានផលប្រយោជន៍ជាច្រើនសំរាប់ប្រជាជន និង បរិស្ថាន:

- តំរូវការចំណីអាហារនៅតាមភូមិ និង ទីក្រុងត្រូវបានគេសង្កេតឃើញថាខ្ពស់ជាងការផ្គត់ផ្គង់នៅកន្លែងដែលការធ្វើកសិកម្មនៅទីក្រុងមិនអាចធ្វើបាន។ អ្នកនេសាទពឹងផ្អែកលើការផ្គត់ឱ្យផ្គង់ដែលមកពី "កំពង់ផែក្រុង" ដូចជាកំពង់ផែ Atijere, Igbobini, និង Mahin។ គ្រួសារស្ទើតែពាក់កណ្តាលបានចំណាយប្រហែល ៥០-៧៥% នៃប្រាក់ចំណូលបានមកពីការនេសាទលើចំណីអាហារ។
- នៅកន្លែងដែល UA មានការអនុវត្តន៏បានល្អ តំលៃលក់រាយនៃបន្លែ និង ដំណាំមើម មានតំលៃទាបជាងនៅតំបន់ដែលមិនអាចធ្វើ UA បាន។
- ផលិតផលដែលផលិតដោយខ្លួនឯងបានផ្តល់ចំណីអាហារ ដល់គ្រួសារដែលមានប្រាក់ចំណូលទាប ដែលមិនមានលទ្ធភាពទិញ
- ការជះឥទ្ធិពលនៃ UA លើសុខមាលភាពរបស់សហគមន៏មានកំរិតខ្ពស់នៅតំបន់ឆ្នេរភាគកណ្តាល ដូចជា Aiyetoro, Ajegunle, Idiogba និង Mahin។ កសិករ និង អ្នកនេសាទ បានរួមវិភាគទានដល់សុខមាលភាពសហគមន៏ តាមរយៈ ការបង្កើតការងារធ្វើដល់យុវវ័យ និង អ្នកដែលបានបញ្ចប់មធ្យមសិក្សា ដែលជួយដល់ការស្រោចទឹក និងថែរក្សាសួនច្បារ និង ដំណាំប្រចាំឆ្នាំ ដូចជា ម្នាស់ ពោត ត្រប់លាវ និង ត្រសក់។ អ្នកផលិតដើររកទីផ្សារដោយខ្លួនឯង។
- ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុង UA ដោយពួកគេចូលរួមនៅក្នុងសកម្មភាពដូចជា ការធ្វើចំការ ប្រមូលផល និង លក់ផលិតផល។
- បើគិតជាលុយ ប្រាក់ចំណូលដែលបានមកពីការនេសាទគឺខ្ពស់ជាងពីការធ្វើកសិកម្មនៅទីក្រុងប្រហែល ៦៥%។ ប៉ុន្តែអ្នកនេសាទនៅតែចង់ធ្វើ UA ជាមួយនេសាទដោយមូលហេតុពួកគេមានចំណីអាហារច្រើនយ៉ាងសំរាប់គ្រួសារ។

*ការប្រើប្រាស់ទឹក*

ទឹកដែលមនុស្សប្រើប្រាស់គឺបានមកពី ទឹកភ្លៀង អណ្តូងខួង ឬ អណ្តូងជីកដៃ និង ព្រែក ទន្លេ និង ប្រឡាយ។ ជាពិសេស ៨០% នៃតំរូវការរបស់គ្រួសារគឺបានមកពីប្រភពទឹកទាំងនេះ នៅតំបន់ដូចជា Mahin, Idiogba, Ajegunle, Ugbonla, Kiribi និង Gbolowo។ ទឹកដែលប្រើប្រាស់សំរាប់កសិកម្មគឺបានមកពីប្រឡាយ និង ទន្លេ នៅគ្រប់ទីក្រុងនៃតំបន់ដែលធ្វើការសិក្សា។

កសិកម្មនៅទីក្រុង និង ជនបទ ហាក់ដូចជាប្រើប្រាស់ទឹកគ្រប់ប្រភេទ។ ស្ទើរតែគ្រប់ទីក្រុងតំបន់ឆ្នេរដែលបានសិក្សា ជាង ៧៥% នៃវាលស្រែត្រូវបានស្រោចស្រពដោយប្រើប្រភពទឹកដោយផ្ទាល់ពីព្រែក ហើយស្ទើតែទាំងអស់គឺស្ថិតនៅតំបន់ទំនាបលិចទឹក។ ជាង៩០%នៃតំបន់យកសំណាក ប្រើប្រាស់ទឹកដែលមិនមានការសំលាប់មេរោគគ្រប់ប្រភពទឹកទាំងអស់។ បញ្ហាសុខភាពដែលទាក់ទងនឹងការប្រើប្រាស់ទឹករួមមានៈ ជំងឺរាករុំរ៉ៃ ជំងឺគ្រុនពោះវៀន និង ជំងឺដែលទាក់ទងនឹងការប្រើប្រាស់ទឹកផ្សេងទៀត។ គុណភាពទឹកដូចគ្នាត្រូវបានគេរកឃើញថាយកទៅប្រើប្រាស់សំរាប់គោលបំណង មនុស្ស សត្វ និង កសិកម្ម។

*សន្និដ្ឋាន*

បញ្ហា គុណភាពទឹក អនាម័យ សុខភាព គឺមានជាក់ស្តែងនៅតំបន់សិក្សា។ គ្មានបង្គន់ និង ការបោះចោលសំរាមពីទីក្រុងធ្វើឱ្យទឹកកខ្វក់។ សហគមន៏ជនបទ តិចជាង ២៥%មានទឹកស្អាតប្រើប្រាស់។ បញ្ហាទឹកតែមួយគត់បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពមនុស្សពេញវ័យ និង លើអត្រារស់របស់កូនក្មេងនៅក្នុងតំបន់សិក្សា។

*ឯកសារយោង*


Hatziolos M, Lundin, C G and Alm, A 1994 *Africa: A Framework for Integrated Coastal Zone Management*. Africa Environmentally Sustainable Development Division, The World Bank.

Mougeot, L J A 2000 Urban Agriculture: Definitions, Presence, Potentials and Risks. In Bakker, N et al (eds), *Growing Cities, Growing Food: Urban Agriculture on the Policy Agenda. A Reader on Urban Agriculture* (pp 1-42). Proceedings of a workshop organized by GTZ, CTA, ACPA, SIDA and DSE. Havana, Cuba, October 1999.

Odada, E O 2002 The Impact of Human Activities on Africa's Coastal and Marine Areas and the Implications for Sustainable Development. In Arthurton, R S et al (eds), *African Basins: LOICZ Global Change Assessment and Synthesis of River Catchment-Coastal Sea Interaction and Human Dimensions* (pp 71-80). LOICZ Reports and Studies No 25.



*Yemi Akegbejo-Samsons* ធ្វើការនៅនាយកដ្ឋានវារីវប្បកម្ម និង គ្រប់គ្រងវិស័យជលផលនៃសកលវិទ្យាល័យកសិកម្ម *Abeokuta* ប្រទេសនីហ្សេរីយ៉ា ។ យើងអាចទាក់ទងតាមរយៈ < samsons56@yahoo.co.uk > ។

# ការវិភាគការចិញ្ចឹមជីវិត:   បទពិសោធន៍ជាក់ស្តែងពីការប្រើប្រាស់ PRA

*Pham Minh Tam និង Trinh Quang Tu*

## សេចក្តីផ្តើម

ការវាយតំលៃជនបទដោយមានការចូលរួម (PRA) មានសារៈសំខាន់ក្នុងការវាយតំលៃស្ថានភាព និង ការជះឥទ្ធិពលនៃគំរោង និង កម្មវិធី។ PRA ជាទូទៅគឺជាជំហានតំបូងនៃដំណើរការធ្វើផែនការ ដែលក្នុងនោះសហគមន៍មានតួនាទីកាន់តែសំខាន់។ PRA គឺមានប្រជាជនចូលរួមនៅក្នុងការផ្លាស់ប្តូរពត៌មាន និង វាយតំលៃស្ថានភាពជាក់ស្តែង។ ក្នុងករណីខ្លះ ការអនុវត្តន៍ PRA យើងមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ ដោយសារយើងនៅធ្វើដើម្បីយកបទពិសោធ។ ដូច្នេះ យើងចង់ចែករំលែកអ្វីដែលយើងបានរៀន តាមរយៈគំរោងដែលផ្តល់មូលនិធដោយ UNDP មានឈ្មោះថា"វាយតំលៃការចិញ្ចឹមជីវិតដោយនិរន្តរភាពនៃប្រជាជនក្រីក្រនៅតំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេសវៀតណាម" និង ការងារវិភាគការចិញ្ចឹមជីវិតដែលផ្តល់មូលនិធិដោយ DFID។

## ដំណើរការនៃការវិភាគការចិញ្ចឹមជីវិត

យើងបានបញ្ចូលវិធីសាស្ត្រ PRA និង ការប្រមូលទិន្នន័យបន្ទាប់បន្សំនៅថ្នាក់ ខេត្ត ស្រុក ឃុំ និង ភូមិ ដោយផ្តោតជាសំខាន់លើស្ថានភាពក្រីក្រ និង ជីវជាតិ។ នៅកំរិតគ្រួសារ យើងបានវិភាគប្រពន្ធ័កសិដ្ឋាន ស្ថានភាពក្រីក្រ និង ជីវជាតិ និងរកមើលនូវមុខរបរដែលអាចកំពស់ជីវភាព។ ឧទាហរណ៏ យើងប្រៀបធៀបការចិញ្ចឹមត្រី ជាមួយសកម្មភាពផ្សេងទៀតក្នុងប្រពន្ធ័កសិកម្ម លើផ្នែក តំលៃ ផលចំណេញ និង ភាពរងគ្រោះ ដើម្បីធ្វើការសំរេចចិត្តថាតើត្រូវបញ្ឈប់ ឬ បន្តការចិញ្ចឹមត្រី។

បច្ចេកទេសសំខាន់ក្នុងការប្រមូលទិន្នន័យគឺ ការសំភាសន៏តាមគ្រួសារ ជាមួយបុរស និង ស្ត្រី ការពិភាក្សាជាក្រុម និង ការសំភាសន៏ជាមួយអ្នកផ្តល់ពត៌មានសំខាន់ៗនៅក្នុងសហគមន៏។ នៅក្នុងភូមិ គ្រួសារត្រូវបានបែងចែកជាក្រុមមួយ ឬ ច្រើន ផ្អែកទៅលើលក្ខខណ្ឌដូចជា ជនជាតិ ប្រាក់ចំណូល មុខរបរ កំរិតវប្បធម៌ ឬក៏អ្វីៗផ្សេងទៀតដូចជា ភាពងាយរងគ្រោះ និង គ្រួសារដែលមានជីវភាពគ្រាន់បើ។

## បទពិសោធដែលទទួលបាន

*ការប្រើប្រាស់* PRA Tools

បទពិសោធដែលយើងទទួលបានក្នុងការប្រើប្រាស់ PRA Tools រួមមាន:

- យើងគួររៀបចំបញ្ជីពត៌មានដែលយើងចង់ប្រមូល ប៉ុន្តែជៀសវាងប្រើប្រាស់បញ្ជីសំនួរ និង ការប្រើប្រាស់ពាក្យបច្ចេកទេសច្រើនពេក។ ជាញឹកញាប់ដែលបញ្ហាជាច្រើនយើងមិនបានដឹង និង មិនបានគិតដល់។ សំនួរគួរតែទាក់ទងទៅនឹងការអង្កេតរបស់យើង ដោយប្រើប្រាស់សំនួរ អ្វី នៅពេលណា នៅកន្លែងណា អ្នកណា ហេតុអ្វី និង ដូចម្តេច?
- យើងគួរសួរសំនួរបើកដែលផ្តល់ពត៌មានបានច្រើនជាងសំនួរបិទ។ ពត៌មានដែលប្រមូលបានអាចផ្ទៀងផ្ទាត់តាមរយៈការពិនិត្យប្រៀបធៀបជាមួយប្រជាជនផ្សេងទៀត និង ពី Tools ផ្សេងទៀត

- យើងគួរប្រើ Tools ផែនទីធនធាន និង ពំនុះកាត់ទទឹងមុនគេ។ វាអាចជួយយើងឱ្យយល់ដឹងពីបញ្ហាទូទៅក្នុងភូមិ មុនពេលយើងប្រើប្រាស់ Tools ផ្សេងទៀត។ ឧទាហរណ៍ ពំនុះកាត់ទទឹង រួមផ្សំជាមួយការដើរសំភាសន៍ជាមួយ អ្នកផ្តល់ពតិមានសំខាន់ និង អនុញ្ញាតិឱ្យយើងសួរសំនួរ និង ចំលើយកាន់តែជ្រៅជាងនៅក្នុងការិយាល័យ។

*ការសរសេររបាយការណ៍នៅនឹងកន្លែង*

វាជាសំខាន់ដែលយើងត្រូវកត់ត្រារាល់ពតិមានទាំងអស់នៅនឹងកន្លែងនៅពេលដែលសមាជិកនៃក្រុមនៅជុំគ្នា។ ការសរសេររបាយការណ៍មានភាពងាយស្រួល ដោយសរសេរពីដំណើរការប្រចាំថ្ងៃ និង សរសេរសង្ខេបជាដ្យ៉ាក្រាមដែលបានមកពី ការប្រើប្រាស់ PRA Tools ។

*កំណត់ហេតុប្រចាំថ្ងៃ និង ការកត់ត្រា*

កំណត់ហេតុប្រចាំថ្ងៃផ្ទាល់ខ្លួន និង ការកត់ត្រាគួរផ្តោតលើតើអ្វីដែលអ្នក និង អ្នកខាងក្រៅចង់ឱ្យការងារកាន់តែប្រសើរ។ តើបញ្ហានៅកន្លែងណា? តើយើងអាចធ្វើអ្វីខ្លះដើម្បីជៀសវាងបញ្ហាទាំងនេះ? តើអ្នកណាអាចផ្តល់នូវដំណោះស្រាយខ្លះ? តើយើង គិតថាមានកំហុសឆ្គងអ្វីខ្លះ? តើយើងទទួលបានបទពិសោធអ្វីខ្លះ?

*ធានាឱ្យមានការចូលរួមពីប្រជាជនក្រីក្រ*

វាជាទំនោរមួយដែលអ្នកក្រមិនអាចចូលរួមនៅក្នុងសកម្មភាពសហគមន៍ពីព្រោះ:

- ពួកគេប្រហែលគ្មានការទុកចិត្តខ្លួនឯង ឬក៏មានការភ័យខ្លាចក្នុងការចូលរួម។ ពួកគេប្រហែលមានអារម្មណ៍ឃ្លាត ឆ្ងាយពីដំណើរការធ្វើការសំរេចចិត្ត និង មិនរវីរវល់ពី កម្មវិធី ឬគោលនយោបាយរបស់រដ្ឋាភិបាល។
- ក្រុមសិក្សាប្រហែលជាចង់ឱ្យអ្នកមានគ្រាន់បើចូលរួមក្នុងសកម្មភាព ដោយសារតែពួកគេងាយស្រួលធ្វើការជាមួយ និង យើងចង់បង្ហាញពីលទ្ធផលល្អ ប៉ុន្តែចង់បង្ហាញថាគោលបំណងសំខាន់របស់យើងគឺធ្វើការជាមួយប្រជាជនក្រីក្រ។

យើងត្រូវធានាថាក្រុមក្រីក្របំផុតនៅក្នុងសហគមន៍ចូលរួម និង មានមតិនៅគ្រប់សកម្មភាព។

*ធានាឱ្យមានការចូលរួមពីស្ត្រី*

ស្ត្រីតែងតែមានឱកាសតិចតួចក្នុងការចូលរួម ហើយការងារអភិវឌ្ឍន៏ និង សង្គម មិនសូវនឹកនារដល់ ជាពិសេសនៅតំបន់ ជនបទ។ វាជាការសំខាន់ដែលស្ត្រីគួរតែបញ្ចូលទៅក្នុងដំណើរការចូលរួម ដោយសារ:

- តំរូវការ និង អាទិភាពរបស់គេមានភាពខុសគ្នាទៅនឹងបុរស ហើយមានការគិតគូរគ្រួសារជាង។ យើងគួរតែរក ឱកាសនិយាយជាមួយទាំងបុរស និង ស្ត្រី។
- ស្ត្រីដើរតួរសំខាន់នៅក្នុងការងារអភិវឌ្ឍន៏ជាពិសេសកាងារដូចជាការចិញ្ចឹមត្រីដែលនៅជិតផ្ទះ។

**សន្និដ្ឋាន**

ដោយសារវាជាការងារអនុវត្ត PRA បានរាប់បញ្ចូលការចូលរួមនៅក្នុងការស្រាវជ្រាវ ដូច្នេះចាំបាច់ត្រូវការជំនាញ អ្នកសំរបសំរួល និង អ្នកធ្វើសំភាសន៍។ នៅក្នុងការធ្វើ PRA យើងគួរប្រើប្រាស់ Tools ឱ្យបានសមស្របទៅតាមស្ថែង ជាពិសេស

នៅតំបន់ជនបទ និង តំបន់ភ្នំ។ យើងក៏អាចរួមផ្សំ PRA Tools ជាមួយវិធីសាស្រ្តផ្សេងៗទៀតដូចជា សំនួរ និង ការសំភាសន៏ ដើម្បីសំរេចបានលទ្ធផលល្អ។

## ឯកសារយោង

ARMP (undated) *Poverty and Aquatic Resources in Vietnam: An Assessment of the Role and Potential of Aquatic Resource Management in Poor People's Livelihoods*. Bangkok: Aquatic Resources Management Programme, Network of Aquaculture Centres in Asia-Pacific and DFID South East Asia.

DFID 2000 *Sustainable Livelihoods Guidance Sheets*. London: Department for International Development.

UNDP 2001 *Analysis of Sustainable Livelihoods of the Poor in Northern Uplands of Vietnam*. Project VIE/98/009/01/NEX. United Nations Development Programme.

*Pham Minh Tam* និង *Trinh Quang Tu* ធ្វើការជាមួយនាយកដ្ឋានផ្សព្វផ្សាយ និង ស្រាវជ្រាវ វិទ្យាស្ថានវារីវប្បកម្មលេខ ១ Bac Ninh ដែលមានទីតាំងនៅជិតទីក្រុងហាណូយ ។ យើងអាចទាក់ទងតាមរយះ < minhtam1977@yahoo.com > និង < vipavadi2@yahoo.com > ។

# យុទ្ធសាស្ត្រចិញ្ចឹមជីវិតដោយនិរន្តរភាពក្នុងការអភិវឌ្ឍន៍វិស័យផលផល
# ដើម្បីកាត់បន្ថយភាពក្រីក្រនៅភាគអគ្នេយ៍នៃប្រទេសវៀតណាម

*Nguyen Van Tu* និង *Nguyen Minh Duc*

## ប្រើយុទ្ធសាស្ត្រការចិញ្ចឹមជីវិតដោយនិរន្តរភាពក្នុងគំរោង AIT-AOP

គំរោងដែលផ្តល់មូលនិធិដោយ SIDA គំរោង "ការអភិវឌ្ឍន៍ជនបទតាមរយៈការគ្រប់គ្រងធនធានវារីជាតិ" នៃវិទ្យាស្ថានបច្ចេកវិជ្ជាអាស៊ី (AIT-AOP) បានអនុវត្តនៅខេត្តភាគអគ្នេយ៍នៃប្រទេសវៀតណាមតាំងពីឆ្នាំ ១៩៩៤។ គោលបំណងរបស់គំរោងគឺលើកកំពស់ជីវភាពរបស់ប្រជាជនក្រីក្របំផុតនៅជនបទតាមរយៈការគ្រប់គ្រងធនធានវារីជាតិដោយនិរន្តរភាព។ សកម្មភាពសំខាន់ៗ រួមមានការសាកល្បងចិញ្ចឹមត្រីនៅកសិដ្ឋាន និង លើកកំពស់សមត្ថភាពរបស់មជ្ឈមណ្ឌលផ្សព្វផ្សាយកសិកម្មខេត្ត (AEC) អ្នកចិញ្ចឹមត្រីជាលក្ខណៈគ្រួសារមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់ការបង្កើនប្រាក់ចំណូលសំរាប់គ្រួសារក្រីក្រ។ គោលបំណងនៃការធ្វើវិភាគការចិញ្ចឹមជីវិតដោយនិរន្តរភាពគឺដើម្បីៈ

- វិភាគស្ថានភាពផលិតកម្ម ក៏រិតជីវភាព និង ធនធានចិញ្ចឹមជីវិតរបស់កសិករ និង អ្នកនេសាទក្រីក្រនៅក្នុងតំបន់គោលដៅ
- រកឱ្យឃើញមុខរបរសំខាន់ និង ប្រភពប្រាក់ចំណូលសំខាន់របស់កសិករ និង អ្នកនេសាទក្រីក្រ និង ដើម្បីស្វែងយល់តើត្រូវធ្វើអ្វីដើម្បីជួយកាត់បន្ថយភាពក្រីក្ររបស់ពួកគេ
- ស្វែងយល់ពីស្ថាប័ន គោលនយោបាយ និង កត្តាដែលជះឥទ្ធិពលលើការប្រើប្រាស់ធនធានរបស់ប្រជាជនក្រីក្រ និង ដើម្បីជួយដល់អាជ្ញាធរមូលដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ បង្កើតយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង និង លុបបំបាត់ភាពអត់ឃ្លានឱ្យបានសមស្របតាមរយៈការគ្រប់គ្រងធនធានវារីជាតិ
- បង្កើតមូលដ្ឋានទិន្នន័យដើម្បីអភិវឌ្ឍន៍ផែនការសំរាប់សកម្មភាពគំរោងសហប្រតិបត្តិការ ដែលមានទិសដៅជួយដល់ប្រជាជនក្រីក្រលើកកំពស់ជីវភាពរស់នៅតាមរយៈការប្រើប្រាស់ធនធានវារីជាតិកាន់តែប្រសើរ។

### ការអនុវត្តន៍

ដើម្បីអនុវត្តយុទ្ធសាស្ត្រវិភាគការចិញ្ចឹមជីវិតដោយនិរន្តរភាព បុគ្គលិករបស់ AIT-AOP សហការជាមួយអាជ្ញាធរមូលដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ ដូចជា នាយកដ្ឋានកសិកម្ម និង អភិវឌ្ឍន៍ជនបទ (DARD) និង AECs ដើម្បីធ្វើការវាយតំលៃជនបទដោយ ឆាប់រហ័ស (RRA) នៅក្នុងឃុំនៃខេត្តជាដៃគូរ។ ក្រុមចុះអង្កេតបានស្នើរឱ្យជ្រើសរើសឃុំ Hoa Thanh នៃស្រុក Chau Thanh ខេត្ត Tay Ninh, ឃុំ Long Ha នៃស្រុក Phuoc Long ខេត្ត Binh Phuoc និង ឃុំ Thanh Son នៃស្រុក Tan Phu ខេត្ត Dong Nai។ ឃុំទាំងនេះគឺជាឃុំក្រីក្រ ប៉ុន្តែមានសក្តានុពលក្នុងការអភិវឌ្ឍន៍ធនធានវារីជាត។

មុនពេលចាប់ផ្តើមធ្វើអង្កេតគំរោង AIT-AOP បានបំពាក់បំប៉នបុគ្គលិកមូលដ្ឋានលើយុទ្ធសាស្ត្រចិញ្ចឹមជីវិតដោយនិរន្តរភាព។ បន្ទាប់មក ក្រុមចំរុះត្រូវបានបង្កើតឡើងដោយមានបុគ្គលិកមកពី DARD, AEC កសិកម្មស្រុក និង ផ្នែកសេដ្ឋកិច្ចគណៈកម្មការប្រជាជនឃុំ សហជីពកសិករ និង ស្ថាប័នពាក់ព័ន្ធផ្សេងៗ។ ការវិភាគលើការចិញ្ចឹមជីវិតដោយនិរន្តរភាពត្រូវបានគេធ្វើនៅក្នុងឃុំ៣ ពីខែ កុម្ភៈ ដល់ខែ មេសា ២០០២។ ដោយផ្អែកលើទំរង់ការចិញ្ចឹមជីវិតដោយនិរន្តរភាព វិធីសាស្ត្រវាយតំលៃ

ជនបទដោយមានការចូលរួមត្រូវបានគេយកមកប្រើដើម្បីប្រមូលទិន្នន័យសំរាប់វិភាគលើធនធានចិញ្ចឹមជីវិត គោលនយោបាយ ស្ថាប័ន និង ដំណើរការដែលប៉ះពាល់ដល់ការចិញ្ចឹមជីវិត។ ទិន្នន័យស្តីពីបញ្ហា ការលំបាក និង ផលប្រយោជន៍នៃការអភិវឌ្ឍន៍ធនធានវារីជាតក៏ត្រូវបានគេប្រមូល និង វិភាគ។

**លទ្ធផល**

ប្រជាជនក្រីក្រនៅក្នុងឃុំដែលបានធ្វើអង្កេតខ្វះដីដាំដុះ ថវិការ និង បច្ចេកទេស ហើយជាញឹកញាប់ប្រឈមមុខនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីអាកាសធាតុមិនល្អ និង ជំងឺ។ ពួកគេគ្មានលទ្ធភាពទទួកនូវទុនវិនិយោគលើការអភិវឌ្ឍន៍ផលិតកម្មសូម្បីតែពីធនាគាសំរាប់ជនក្រីក្រ និង ធនាគារអភិវឌ្ឍន៍កសិកម្ម។

គ្រួសារក្រីក្រនិមួយៗមានស្ថានភាពដោយឡែក១ពីគ្នា។ ហេតុដូច្នេះហើយបានជាកម្មវិធីកាត់បន្ថយភាពក្រីក្រ និង ភាពអត់ឃ្លានត្រូវតែផ្អែកលើស្ថានភាពគ្រួសារនៅក្នុងបរិបទដូចគ្នាក៏ដោយ។ កម្មវិធីណាក៏ដោយមិនត្រឹមតែមានឥទ្ធិពលដោយផ្ទាល់លើសកម្មភាពចិញ្ចឹមជីវិតរបស់ប្រជាជន ប៉ុន្តែជួយលើការផ្លាស់ប្តូគោលនយោបាយ ឧទា. ឥណទាន និង ការការពារធនធានធម្មជាតិដែលតាមរយៈនេះ ប្រជាជនក្រីក្រអាចទទួលបានផលប្រយោជន៍។ កសិករក្រីក្រមានប្រភពចំណូលសំខាន់មកពី ដំណាំចំការ ចិញ្ចឹមត្រី និង ការចិញ្ចឹមសត្វ។ ពួកគេបានបញ្ជាក់ថាពីភាពចាំបាច់នៃការប្រើប្រាស់នូវធនធានដែលមាននៅក្នុងមូលដ្ឋាន ដូចជា កំលាំងពលកម្ម ដីដាំដុះ និង ជំនួយបច្ចេកទេសពីសេវាកម្មផ្សព្វផ្សាយ សំរាប់អភិវឌ្ឍន៍វារីវប្បកម្មដើម្បីរកចំណូលបន្ថែម។ អ្នកនេសាទក្រីក្រមានប្រភពចំណូលសំខាន់មកពីការនេសាទនៅក្នុងដែនទឹកធម្មជាតិ។ នៅពេលដែលធនធានវារីជាតមានការថយចុះយ៉ាងខ្លាំង ពួកគេត្រូវដាំដំណាំ ឬក៏ស៊ីឈ្នួលគេ។ ហេតុដូច្នេះហើយ ពួកគេត្រូវការនូវប្រពន្ធ័មួយដែលមានសហគមន៍ជាអ្នកការពារដើម្បីលើកកំពស់ធនធានធម្មជាតិ និង ការចាប់ដោយនិរន្តរភាព។

ចាំបាច់ត្រូវបង្កើតក្រុមប្រជាជនក្រីក្រដើម្បីជួយពួកគេឱ្យចែករំលែកនូវចំណេះដឹង និង បទពិសោធន៍ដើម្បីរកនូវបញ្ហា និង ការលំបាក រកនូវដំណោះស្រាយសមស្រប និង ផ្តល់សិទ្ធដល់សហគមន៍។ តាមរយៈក្រុមបែបនេះ អាជ្ញាធរមូលដ្ឋាន មជ្ឈមណ្ឌលផ្សព្វផ្សាយ និង គណៈកម្មការកាត់បន្ថយភាពក្រីក្រ និង គ្រោះអត់ឃ្លានអាចផ្តល់ការជួយឧបត្ថម្ភដោយងាយស្រួលក្នុងការជំនះនូវការលំបាក និង កាត់បន្ថយភាពក្រីក្រ។

**សកម្មភាពជួយឧបត្ថម្ភ**

*ការបង្រៀនពីការចិញ្ចឹមត្រីនៅនឹងកន្លែង ( Farmer field school "FFS" )*

តាមរយៈដំណើរការនៃការវិភាគការចិញ្ចឹមជីវិតដោយនិរន្តរភាព កសិករចង់អភិវឌ្ឍន៍វារីវប្បកម្មជាមធ្យោបាយសំរាប់លើកកំពស់ប្រាក់ចំណូល។ ផ្អែកលើសេចក្តីត្រូវការរបស់កសិករ AEC នៅខេត្តទាំងបីដែលជាដៃគូរបានស្នើរឱ្យ AIT-AOP ជួយបង្កើតការបង្រៀនពីការចិញ្ចឹមត្រីនៅនឹងកន្លែង (FFS)។ យុទ្ធសាស្រ្តផ្សព្វផ្សាយដែលផ្តោតទៅលើ និង ដឹកនាំដោយកសិករបានផ្តល់ ឱកាសឱ្យពួកគេចែករំលែកបទពិសោធន៍ និង រៀនពីបច្ចេកទេសចិញ្ចឹមត្រី។ FFS ក៏បានជួយឱ្យកសិករដឹងពីតំលៃ និង ផលប្រយោជន៍ ធ្វើការសាកល្បង និង ស្វែងរកដំណោះស្រាយសមស្របដើម្បីប្រើប្រាស់ និង គ្រប់គ្រងធនធានធម្មជាតិ។ ការប្រើប្រាស់យុទ្ធសាស្រ្ត FFS នៅក្នុងវារីវប្បកម្មអាចជួយប្រជាជនឱ្យមានតួនាទីកាន់តែសំខាន់ក្នុងការប្រើប្រាស់ធនធានវារីជាតសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ FFSអាចនាំប្រជាជនឱ្យមានការចូលរួមសកម្មក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍នៅកំរិតគ្រួសារ និង សហគមន៍។

*ក្រុមការពារធនធានវារីជាត និង នេសាទ*

កសិករ និង អ្នកនេសាទពឹងផ្អែកលើធនធានវារីជាតនៅអាងទឹកនៅក្នុងឃុំ Long Ha និង នៅវាលលិចទឹក និង ព្រែកនានានៅភាគខាងកើតនៃទន្លេ Vam Co ដើម្បីរកប្រាក់ចំណូល និង ចំណីអាហារ។ ដោយបានដឹងពីសេចក្ដីត្រូវការចាំបាច់ក្នុងការអភិវឌ្ឍន៍ការការពារដោយសហគមន៍ឱ្យកាន់តែមានប្រសិទ្ធិភាព អាជ្ញាធរឃុំ កសិករ និង អ្នកនេសាទបានបង្កើតក្រុមការពារធនធានវារីជាត និង នេសាទ។ ពួកគេបានបង្កើតបទបញ្ជាផ្ទៃក្នុង និង ប្រជុំរៀងរាល់ខែ។ សមាជិកទាំងអស់បានយល់ព្រមឈប់នេសាទនៅតំបន់ពងកូនក្នុងរដូវពងកូន។ ដើម្បីបង្កើនផលស្តុក នៅខែកក្កដា ២០០២ នាយកដ្ឋានកសិកម្ម និង អភិវឌ្ឍន៍ជនបទ (DARD) ខេត្ត Binh Phuoc បានព្រលែងកូនត្រីចំនួន ៨០ គ.ក ចូលទៅក្នុងអាងទឹក។ អាជ្ញាធរមូលដ្ឋាននៃខេត្តតៃនិញក៏មានផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីនៅក្នុងឃុំរបស់ខ្លួន និង អាចកាត់បន្ថយសំពាធលើធនធានធម្មជាតិ និង លើកកំពស់ប្រាក់ចំណូលរបស់ប្រជាជនក្រីក្រ។

**បទពិសោធន៍ដែលទទួលបាន**

យុទ្ធសាស្ត្រវិភាគការចិញ្ចឹមជីវិតដោយនិរន្តរភាពគឺជា Tool មួយដែលជួយប្រជាជនក្រីក្រឱ្យយល់ពីធនធានដែលគេមាន និង មន្ត្រីមូលដ្ឋានឱ្យយល់ពីការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ ហើយជួយពួកគេឱ្យកាន់តែប្រសើរ។ ដើម្បីធ្វើឱ្យការវិភាគការចិញ្ចឹមជីវិតកាន់តែមានប្រសិទ្ធិភាព យើងគួរគិតបញ្ហាដូចខាងក្រោម:

- បង្កើតក្រុមវិភាគការចិញ្ចឹមជីវិត: សមាជិកនៃក្រុមគួរតំណាងឱ្យស្ថាប័ន និង អង្គការដែលធ្វើការយ៉ាងជិតស្និទ និង ជួយដល់ប្រជាជនក្រីក្រ (ឧទា. AECs ខេត្ត)
- រយៈពេលនៃការធ្វើអង្កេតការចិញ្ចឹមជីវិត: ការអង្កេតការវិភាគការចិញ្ចឹមជីវិតគួរធ្វើមិនឱ្យលើសពី ពីរអាទិត្យ តំណាងឱ្យស្ថាប័ន និង អង្គការសំខាន់ៗគួរចូលរួមនៅក្នុងរាល់កិច្ចប្រជុំជាមួយកសិករ និង អ្នកនេសាទក្នុងកំឡុងពេលធ្វើអង្កេត
- សកម្មភាពតាមដាន: ការវិភាគការចិញ្ចឹមជីវិតគឺមានសារៈសំខាន់សំរាប់យល់ដឹងពីកត្តាសំខាន់ដែលជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ។ បន្ទាប់ពីធ្វើការវិភាគការចិញ្ចឹមជីវិត វាជាការចាំបាច់ដែលយើងត្រូវអភិវឌ្ឍន៍ផែនការសកម្មភាពតាមដានឱ្យបានឆាប់រហ័សដោយមានការចូលរួមពីកសិករ និង អ្នកនេសាទ

*Nguyen Van Tu* គឺជាអ្នកគ្រប់គ្រងនៃកម្មវិធី AIT នៅភាគខាងត្បូងនៃប្រទេសវៀតណាម។ យើងអាចទាក់ទងតាមរយៈ < nvantu@hcmuaf.edu.vn >។ *Nguyen Minh Duc* ធ្វើការនៅមហាវិទ្យាល័យជលផល នៃសកលវិទ្យាល័យ Nong Lam នៅទីក្រុងហូជីមិញ។ យើងអាចទាក់ទងតាមរយៈ < nmduc@hcmuaf.edu.vn >។

# ពត៌មានពីទស្សនាវដ្ដីរបស់ STREAM

បោះពុម្ពដោយ STREAM- Support to Regional Aquatic Resources Management
Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand

ក្រុមអ្នកបោះពុម្ពផ្សាយ

Graham Haylor, នាយកនៃគំរោង STREAM

Le Thanh Luu, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅវៀតណាម

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Sonia Seville, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅហ្វីលីពីន

Thay Somony, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅកម្ពុជា

## គោលបំណង

ទស្សនាវដ្ដីរបស់ STREAMបោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម, ទំនាក់ទំនង, និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាងទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់។ ទស្សនាវដ្ដីរបស់ STREAMមានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជនដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុងសហគមន៍។ បញ្ហាមានដូចជាៈ ការរៀនសូត្រ, ការគ្រប់គ្រងជំលោះ, បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន, ការគ្រប់គ្រងធនធានវារិជាត, ច្បាប់, ការចិញ្ចឹមជីវិត, យិនឌ័រ, ការចូលរួម, អ្នកជាប់ពាក់ពន្ធ័, គោលនយោបាយ និង ទំនាក់ទំនង។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្ដី STREAMគឺផ្ដល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរមានដើម្បីឱ្យគេបានលឺ និង មានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ទិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ។ មាតិកាក្នុងទស្សនាវដ្ដី មិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនៈនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ

មនុស្សម្នាក់ៗដោយផ្អែកលើបទពិសោធរបស់ពួកគេ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេ ហើយ STREAMទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ។

## ការចែកចាយ

ទស្សនាវដ្តីរបស់ STREAMអាចរកបានជា ៣ ទំរង់

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្ម ក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក

ទស្សនាវដ្តីរបស់ STREAMលើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធាន វារីជាត និង មនុស្សដែលធ្វើការជាមួយពួកគេ។ ទស្សនាវដ្តីរបស់ STREAMkក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធរបស់ពួកគេនៅក្នុងទំព័រទាំងនេះ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១000 ពាក្យ (ប្រហែល ២ ទំព័រ A4)

អ្នកអាចផ្តល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្តីរបស់ STREAMតាមរយៈ savage@loxinfo.co.th.

ពត៌មានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th

## ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់ )ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈ ពេល៥ឆ្នាំនៃ កម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌល វារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។ គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និងស្ថាប័នផ្សេងៗឱ្យ:

- ប្រើប្រាស់ពត៌មានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ និង
- អាចឱ្យប្រជាជន ក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពល លើជីវិតរបស់ពួកគេ ។

គំរោង នឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៍គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និង ការកសាងសមត្ថភាពដើម្បី:

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានវារីជាតដែលជះឥទ្ធិពលទៅលើជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេងៗគ្នា
- ផ្សព្វផ្សាយពត៌មាន
- ធ្វើបណ្តាញនៅក្នុង/រវាងវិស័យ និងរវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការករកើតនូវការរួបរួមជាដៃគូរ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាង អ្នកជាប់ពាកលពន្ធ័ទាំងអស់ដែលជាប់ទាក់ទិននិងការគ្រប់គ្រងធនធានវារីជាត និងជួយពួកគេឱ្យរួម ចំណែកក្នុងការរៀបចំ, អនុវត្តន៍ និងការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូរត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយៗតាមរយៈក្រុមសំរបសំរួលជាតិ ដែលរួម មាន: អ្នកសំរបសំរួលជាតិ (មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ ទំនង (ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូងដោយ STREAM) ហើយភ្ជាប់ ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ផ្សេងៗ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware( មាន ដូចជា កុំព្យូទ័រ ម៉ាស៊ីនស្កេន...), Software (កម្មវិធីកុំព្យូទ័រ ដូចជា word, excel..), បំពាក់បំប៉ន, ការជួយឧបត្ថម្ភ ដល់បច្ចេកវិទ្យាពត៌មាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ពន្ធ័តាមរយៈ Internet ។

ការសំរបសំរួលជាតិគឺអនុវត្តទៅតាម អត្ថបទយុទ្ធសាស្ត្រនៃប្រទេស(CSP) ដោយមានការពិនិត្យឡើងវិញជារៀង រាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកជាប់ពាក់ពន្ធ័។ CSP រកឱ្យឃើញនូវបញ្ហា, ផ្តោតលើទំនាក់ទំនងក្នុងតំបន់, ធ្វើសំណើរ និង ធ្វើអាទិភាព សកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និងពីកន្លែងផ្សេងៗទៀត (ដោយមាន ការជួយជ្រោមជ្រែងពី STREAM)។

កាិរយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក)ដឹកនាំគំរោង, ផ្តល់នូវតួនាទី សំរបសំរួលក្នុងតំបន់, និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹង ការចិញ្ចឹមជីវិត, ការអភិវឌ្ឍន៏គោលនយោ បាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និង វៀតណាមដែលជាកន្លែងមានឳកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និងលើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៏, មេរៀនត្រូវ បានរៀន, ការជះឥទ្ធិពលត្រូវបានដឹង, ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមាន ទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការ បានជា ពតិមានដល់ ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច។ ទស្សនាវដ្ដីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ។

អាស័យដ្ឋានទំនាក់ទំនង:

STREAM National Communications Hub Managers

| | |
|---|---|
| Cambodia | : Sem Viryak, < cfdo@camnet.com.kh > |
| India | : Rubu Mukherjee < rubumukherjee@rediffmail.com > |
| Nepal | : Nilkanth Pokhrel < agroinfo@wlink.com.np > |
| Philippines | : Elizabeth Gonzales < streambfar-phil@skyinet.net > |
| Vietnam | : Nguyen Song Ha < nguyensongha@fpt.vn > |